អាចទទួលទ្រង់ថ្ងៃនេះ ដោយសារអំពាវនាវដល់
ព្រះនាមទ្រង់ដោយចិត្តជឿដើម្បីឱ្យបានសង្គ្រោះ
ចូរសូមព្រះគ្រីស្ទយេស៊ូវឱ្យសង្គ្រោះអ្នកថ្ងៃនេះ
ដូចខាងក្រោមនេះ

ឱព្រះយេស៊ូអើយ ខ្ញុំដឹងថា ខ្ញុំបានធ្វើបាបហើយខ្ញុំមិនអាចលប់អំពើបាបរបស់ខ្លួនចេញបានទេ ប៉ុន្តែខ្ញុំជឿថាទ្រង់អាចជួយខ្ញុំបាន ដូច្នេះសូមអត់ទោសបាបខ្ញុំ ហើយសំអាតខ្ញុំពីគ្រប់ទាំងអំពើបាប ហើយសូមនាំព្រលឹងរបស់ខ្ញុំទៅឋានសួគ៌នៅពេលដែលខ្ញុំស្លាប់ សូមអរព្រះគុណព្រះអង្គដែលបានសង្គ្រោះខ្ញុំនៅថ្ងៃនេះ អាម៉ែន ។

បើអ្នកទើបតែបានទទួលព្រះគ្រីស្ទយេស៊ូវ ហើយអ្នកចង់រៀនថែមទៀត នោះសូមទាក់ទងតាមរយៈខាងក្រោមនេះ ។

ការិយាល័យសំរាប់ទាក់ទង
ប្រអប់ប្រៃសណីយ៍២៥០៦
ភ្នំពេញ៣

# សាសនា

# ចាំបាច់

# ចាំអោយ

# ធ្វើ[illegible]

សាសនាណាក៏ដូចសាសនាណា ព្រោះសាសនាទាំងអស់មានក្រិត្យវិន័យសំរាប់ប្រៀនប្រដៅមនុស្សឱ្យធ្វើល្អ ហើយប្រព្រឹត្តសេចក្តីសុចរិត សាសនាទាំងអស់បង្រៀនថាកុំលួច កុំកុហក កុំលេងស្រី មានក្រិត្យវិន័យច្រើនជាងនេះដែលដូចគ្នា សាសនាជាច្រើនបានបង្រៀនទៀតថា" បើយើងខុសក្រិត្យវិន័យណាមួយដូចជាយើងខុសក្រិត្យវិន័យទាំងអស់" បើមានទឹកសុទ្ធ១កែវ ហើយដាក់ទឹកកខ្វក់សូម្បីតែ១ដំណក់ចូលទៅនាំបង្ខូចទឹក១កែវ បានជាគ្មានអ្នកណាម្នាក់ដែលអាចកាន់តាមក្រិត្យវិន័យរបស់សាសនាណាមួយបានទេ ។ មនុស្សគ្រប់គ្នាអាក្រក់ហើយបានធ្វើបាប គ្មានអ្នកណាសុចរិតសោះសូម្បីតែមួយក៏គ្មានផង គ្មាននរណាដែលអាចកាន់តាមក្រិត្យវិន័យទាំងអស់របស់សាសនាណាមួយបានទេ ។

ព្រះគម្ពីររបស់សាសនាគ្រីស្ទក៏បាននិយាយថា" គ្មានអ្នកណាដែលបានរាប់ជាសុចរិតនៅចំពោះទ្រង់ដោយអាងការប្រព្រឹត្តតាមក្រិត្យវិន័យនោះឡើយ ដ្បិតក្រិត្យវិន័យគ្រាន់តែសំដែងឱ្យស្គាល់អំពើបាបប៉ុណ្ណោះ"។ ដូច្នេះក្រិត្យវិន័យរបស់សាសនាមិនអាចជួយឱ្យយើងត្រលប់ជាសុចរិតបានទេ វាគ្រាន់តែជួយសំដែងឱ្យឃើញអំពើបាបរបស់ខ្លួនតែប៉ុណ្ណោះ ។ បើសិនជាដូច្នេះតើយើងទាំងអស់គ្នាត្រូវជាប់នៅក្នុងអំពើបាបជារាបទៅឬអី ទេយើងនៅមានសង្ឃឹមក្នុងព្រះ គ្មានសង្ឃឹមនៅក្នុងក្រិត្យវិន័យរបស់សាសនា ប៉ុន្តែនៅមានសង្ឃឹមក្នុងព្រះ ។

តើព្រះមួយណាអាចជួយមនុស្សយើងបាន ?

សាសនាជាច្រើនថា"ខ្លួនទីពឹងខ្លួន""សង្គ្រោះខ្លួនទៅ""លាងបាបចេញដោយខ្លួនឯង"ប៉ុន្តែព្រះយេស៊ូវបាននិយាយថា"អស់ទាំងមនុស្សនៅចុងផែនដីអើយ ចូរមើលមកអញ ហើយទទួលសេចក្តីសង្គ្រោះចុះ ដ្បិតអញនេះជាព្រះ ឥតមានណាទៀតឡើយ គឺអញ អញនេះហើយជាអ្នកដែលលុបអំពើរំលងរបស់ឯងនេះចេញដោយយល់ដល់ខ្លួនអញ ហើយអញមិននឹកចាំពីអំពើបាបរបស់ឯងទៀតឡើយ" ។ ពីមុនមានម្នាក់បានសួរសំនួរដូចនេះថា"លោកម្ចាស់អើយតើត្រូវឱ្យខ្ញុំធ្វើដូចម្តេចឱ្យបានសង្គ្រោះផង" គេក៏ប្រាប់គាត់ថា"ចូរជឿដល់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទទៅ នោះនឹងបានសង្គ្រោះហើយ"

តើអ្នកត្រូវជឿអ្វីខ្លះអំពីព្រះគ្រីស្ទយេស៊ូវ ដើម្បីឱ្យបានសង្គ្រោះ?

អ្នកត្រូវតែជឿថា ព្រះគ្រីស្ទយេស៊ូវគឺជាព្រះពិតតែមួយ ហើយថាទ្រង់បានសុគតជំនួសបាបរបស់អ្នក ហើយថាទ្រង់បានរស់ពីស្លាប់ឡើងវិញ ហើយថាមានតែព្រះគ្រីស្ទយេស៊ូវតែមួយអង្គគត់ ដែលអាចជួយសង្គ្រោះអ្នកពីបាបបាន ។ បើអ្នកជឿអញ្ចឹង នោះត្រូវតែទុកចិត្តលើទ្រង់ចុះដោយទទួលទ្រង់ជាអ្នកសង្គ្រោះរបស់អ្នក អ្នក